**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៧៣៤ ថ្ងៃសុក្រ ទី២១ ខែសីហា ឆ្នាំ២០០៩



ពលរដ្ឋមួយគ្រួសារនេះគួរឱ្យអាសូរ (តាសោម)

# គ្រួសារអ្នករត់ម៉ូតូឌុបប្រឈមការដាច់បាយ ដោយសារប៉ូលិសចាប់ម៉ូតូ

ខេត្តព្រះសីហនុ : គ្រួសារមួយមានប្តី ប្រពន្ធនិងកូន៣នាក់ បានចេញមុខប្រកាសសុំអន្តរាគមន៍ និងអំពាវនាវសុំជំនួយពីសប្បុរសជននានា ខណៈដែលម៉ូតូរបស់គាត់ត្រូវសមត្ថកិច្ចប៉ូលិសចរាចរផ្លូវគោកឃាត់យកទៅរក្សាទុកតាំងពីថ្ងៃទី៤ សីហាមក ជាហេតុធ្វើឱ្យពួកគាត់ប្រឈមមុខនឹងការខ្វះខាតយ៉ាងខ្លាំង ដែលអាចនឹងដាច់បាយនៅថ្ងៃខាងមុខ។

តាមបុរសជាមេគ្រួសារម្នាក់ឈ្មោះនាក់ ទូច ភេទប្រុស អាយុ៤៨ឆ្នាំ មានស្រុកកំណើត នៅភូមិជ្រោយស្លែង ឃុំសំបកទទឹម ស្រុកគីរីវង់ ខេត្តតាកែវ បាននិយាយថា គាត់មានប្រពន្ធ ឈ្មោះអ៊ិន ផល្លី អាយុ៣៨ឆ្នាំ មានកូនក្នុងបន្ទុក៣នាក់ ដែលកូនទី១-ឈ្មោះកប ចិន ភេទប្រុស អាយុ១៣ឆ្នាំ កូនទី២ ឈ្មោះកប បុល ភេទ ប្រុស អាយុ១១ឆ្នាំ និងកូនទី៣ ឈ្មោះកប វិណា ភេទស្រី អាយុ២ឆ្នាំ បច្ចុប្បន្នស្នាក់នៅផ្ទះជួលក្នុងក្រុម១ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ

ខេត្តព្រះសីហនុ។ គាត់បន្តថា កាលពីចាប់ដៃគ្នាដំបូងជាមួយប្រពន្ធគាត់គឺពួកគាត់រស់នៅឯស្រុកកំណើតឯណោះទេ លុះមកដល់ឆ្នាំ១៩៩០ ក៏នាំប្រពន្ធមករស់នៅក្រុងព្រះសីហនុ ដែលកាលនោះគាត់ធ្វើជាកម្មករសំណង់ជាមួយប្រពន្ធ។ ពេលធ្វើជាកម្មករសំណង់ គាត់សន្សំលុយធ្វើកូនខ្ទមបានមួយ សង់នៅលើដីមួយកន្លែងក្បែរអូរនៅម្តុំទួលខ្សាច់ ស្ថិតក្នុងសង្កាត់លេខ៤ ក្រុងព្រះសីហនុ តែអកុសលកូនទី១របស់គាត់បានធ្លាក់ខ្លួនឈឺធ្ងន់ ។ ក្នុងជីវិតជាកម្មករសំណង់រកមួយថ្ងៃសំរាប់តែមួយថ្ងៃ គាត់ពុំមានលុយដើម្បីព្យាបាលជំងឺកូនទេ ហើយពេលនោះគាត់ និងប្រពន្ធក៏សំរេចចិត្តលក់ដី និងកូនខ្ទមនោះបានលុយជាង ១០ម៉ឺនរៀល ដើម្បីព្យាបាលជំងឺកូន រួចក៏មកជួលផ្ទះគេនៅរហូតមក ។

បុរសឈ្មោះនាក់ ទូច បានរៀបរាប់បន្តទាំងទឹកមុខស្រពោនថា មិនដឹងថាជាតិមុនរូបគាត់ធ្វើអ្វីខ្លះទេ ទើបជាតិនេះសែនអភ័ព្វយ៉ាងនេះ ប៉ុន្តែទោះជាយ៉ាងណាគាត់នៅតែខំតស៊ូធ្វើជាកម្មករសំណង់រហូតដល់ ឆ្នាំ២០០៧ សន្សំលុយបានចំនួន១៥០ដុល្លារ ក៏សំរេចចិត្តចងការលុយគេចំនួន២៥០ដុល្លារទៀត យកមកបង្គ្រប់ទិញម៉ូតូ១គ្រឿងតំលៃ៤០០ដុល្លារ ម៉ាកវ៉េវ ពណ៌ខៀវ អត់ពន្ធ ស៊េរីឆ្នាំ២០០៣ ដើម្បីប្តូរមុខរបរពីកម្មករសំណង់មករត់ម៉ូតូឌុបវិញ។ ការរត់ម៉ូតូឌុបនេះគាត់រកចំណូលពុំបានច្រើនដូចគេទេ គឺបាន១០.០០០រៀល ទៅ១៥.០០០រៀលប៉ុណ្ណោះក្នុងមួយថ្ងៃ ព្រោះគាត់ពុំសូវចេះហៅម៉ូយដូចគេដទៃ ។ លុយដែលគាត់រកបាន គឺមួយផ្នែកសងទៅម្ចាស់លុយបន្តិចម្តងៗ មួយផ្នែកផ្គត់ផ្គង់កូនទៅសាលា ទិញអង្ករ និងថ្លៃឈ្នួលផ្ទះដែលត្រូវបង់ចំនួន៣០.០០០រៀលក្នុងមួយខែ ។

លុះនៅថ្ងៃទី៤ សីហា ម៉ូតូរបស់គាត់ត្រូវសមត្ថកិច្ចប៉ូលិសចរាចរផ្លូវគោកចាប់ឃាត់យកទៅរក្សាទុក ដែលគិតត្រឹមថ្ងៃទី១៩ សីហា គឺមានរយៈពេល១៥ថ្ងៃហើយ ជាហេតុធ្វើឱ្យគាត់ត្រូវដើរខ្ចីលុយគេបន្ថែមដើម្បីទិញអង្ករមកផ្គត់ផ្គង់គ្រួសារ ព្រោះគាត់ពុំមានម៉ូតូរត់ឌុបទៀត។ ពីមុនគាត់អាចទិញអង្ករម្តង២គីឡូក្រាម ទៅ៥គីឡូក្រាម ឥឡូវគាត់មានលទ្ធភាពទិញ២កំប៉ុង ឬ៣កំប៉ុងតែប៉ុណ្ណោះ។ ដោយសារការខ្វះខាតពេក គាត់ក៏សំរេចចិត្តទៅធ្វើជាកម្មករទូកជាបណ្តោះអាសន្ន តែជាអកុសលរដូវនេះទូកចេញបានម្តងម្កាលតែប៉ុណ្ណោះព្រោះរលកសមុទ្រធំ ។



នាក់ ទូច ប្រឹងបីកូនចូលរួមក្នុងការតវ៉ាក្រែងបានម៉ូតូមកវិញគ្រាន់ចិញ្ចឹមផ្ទាំង តែផ្ទុយទៅវិញជាងកន្លះខែហើយគ្មានប្រាក់បង់ពន្ធ ម៉ូតូនៅតែជាប់ឃុំ (រូបថត តាសោម)

គាត់បន្តថា ក្នុងមួយឆាកជីវិតរបស់គាត់វាឆ្អែតហើយនឹងភាពលំបាក ប៉ុន្តែពេលនេះវាលើសពីការលំបាកមួយរយមួយពាន់ដង ទៅទៀត ព្រោះងាកឆ្វេងកូនសុំលុយទិញចំណី ងាកស្តាំប្រពន្ធរកលុយទិញអង្ករ ឯម្ហូបអាចដើរសុំត្រីគេតាមទូក ងាកទៅមុខ ដល់ថ្ងៃឈ្នួលផ្ទះគេ ងាកទៅក្រោយលុយត្រូវសងគេ តើក្នុងស្ថានភាពបែបនេះក្នុងនាមគាត់ជាមេគ្រួសារមានការលំបាក យ៉ាងណា? ដូចនេះរូបគាត់មានតែលើកម្រាមដៃដប់ សូមក្តីសន្តោសពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន មេត្តាជួយអន្តរាគមន៏ដល់ក្រុមគ្រួសារគាត់ផង និងសុំឱ្យក្រសួងពាក់ព័ន្ធមេត្តាលើកលែងការបង់ពន្ធសំរាប់រូបគាត់ផង ព្រោះរូបគាត់គ្មានលទ្ធភាព បង់ពន្ធឡើយ និងសូមអំពាវនាវដល់បងប្អូនសប្បុរសជនទាំងអស់មេត្តាជួយសង្គ្រោះដល់ក្រុម គ្រួសារគាត់ផង ដើម្បីឱ្យគាត់មានលទ្ធភាពចិញ្ចឹមក្រុមគ្រួសារឡើងវិញ ព្រោះគាត់នឹងគ្មានលទ្ធភាពបង់ពន្ធទេ ប្រសិនបើ គ្មានជំនួយពីបងប្អូនសប្បុរសជន ។